**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខៈ ៤៩០២ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ២១៨៣ ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធី នៃការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល
- យោងលិខិតលេខ១០៧៧ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ១០៥/២១ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

## សម្រេច

**ប្រការ ១ ._**

ត្រូវបានចុះឈ្មោះ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលស្ថិតនៅអគារF ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ប្រការ ២ ._**

**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុក នៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ._**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......... ខែ.......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ប៊ុន ហុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៤ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

Cambodian Water Supply Association

( នីតិបុគ្គល )


លេខទូរស័ព្ទទំនាក់ទំនង៖

០៩៧ ៧១៧ ៩៩៥៣ ឬ ០១៧ ៧៩៩ ៣៣៧ ឬ ០៧០ ៧៩៩ ៣៣៧

អ៊ីម៉ែល info@cwa.org.kh

# អំពីសាចសារ

៚ ✻ ៚

ដោយសម្លឹងឃើញថា ការចងក្រងប្រមូលផ្តុំគ្នាមូលជាធ្លុង ចងជាចង្កឹះមួយបាច់ គឺជាកម្លាំងសាមគ្គីគ្នាដ៏រឹងមាំ ដើម្បីរួមគ្នាធ្វើឲ្យកាន់តែប្រសើរឡើងនូវការពង្រីក និងពង្រឹងមូលដ្ឋានសមត្ថភាពជំនាញវិជ្ជាជីវៈក្នុងវិស័យទឹកស្អាត និងការជួយគ្នាទៅវិញទៅមកផង **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយមានស្ថាបនិកចំនួន ៣រូប និងត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឲ្យចុះឈ្មោះក្នុងបញ្ជីសមាគមតាមរយៈលិខិតលេខ ១០៧៧ សជណ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ ២០១២ របស់ក្រសួងមហាផ្ទៃ ដោយទទួលបាននូវសិទ្ធិជានីតិបុគ្គល ដើម្បីអាចធ្វើសកម្មភាពស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា និងការពារផលប្រយោជន៍ស្របច្បាប់របស់សមាជិក ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការ រវាងអ្នកពាក់ព័ន្ធនានាជាមួយនឹងអាជ្ញាធរសាធារណៈ។

ដោយមានការរីកចម្រើន ទំនុកចិត្ត និងការទទួលបាននូវការគាំទ្រពីអាជីវករ ក្រុមហ៊ុន សហគ្រាសប្រតិបត្តិករទឹកស្អាតនានា និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា សមាគមបានសម្រេចបញ្ចូលសមាជិកបន្ថែមមានទាំងរូបវន្តបុគ្គល និងនីតិបុគ្គលនៅក្នុងវិស័យទឹកស្អាតនាពេលបច្ចុប្បន្ននេះ។ លើមូលដ្ឋាននេះ និងដោយការវិវត្តនានានៃស្ថានភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសដើម្បីអនុវត្តឲ្យស្របតាមស្មារតី នៃប្រកាសលេខ **២១៩៣ ប្រក** ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល សមាគមចាំបាច់ត្រូវរៀបចំបែបបទ និងសំណុំឯកសារឡើងវិញដើម្បីស្នើសុំចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់**នីតិបុគ្គល** នៅក្រសួងមហាផ្ទៃ។

ផ្អែកតាមបរិការណ៍នេះ ដើម្បីធ្វើឲ្យកាន់តែល្អប្រសើរឡើង និងចូលរួមចំណែកយ៉ាងសកម្មទៅក្នុងសកលភាវូបនីយកម្មសម័យបច្ចេកវិទ្យាទំនើបក្នុងវិស័យទឹកស្អាត និងដើម្បីជាមូលដ្ឋានគ្រឹះក្នុងការឯកភាពគ្នាសាមគ្គីភាពតែមួយទុកជាមរតកសម្រាប់អ្នកជំនាន់ក្រោយ គោរពប្រតិបត្តិ និងអនុវត្ត ថ្នាក់ដឹកនាំ និងសមាជិកបានឯកភាព ស្រុះស្រួលគ្នារៀបចំនូវលក្ខន្តិកៈដ៏ឧត្តុង្គឧត្តមនេះឡើងដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

ស.អ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ
# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
Cambodian Water Supply Association
(នីតិបុគ្គល)

## ជំពូកទី ១
## ទស្សនៈវិស័យ គោលបំណង បេសកកម្ម និងសកម្មភាព

### ប្រការ ១._ អំពីទស្សនៈវិស័យ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានទស្សនៈវិស័យ គឺចង់ឃើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានសេវាទឹកស្អាត និងអនាម័យ ដែលមានគុណភាពស្របតាមស្តង់ដាថ្នាក់ជាតិ។

### ប្រការ ២._ អំពីគោលបំណង

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

### ប្រការ ៣._ អំពីបេសកកម្ម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានបេសកកម្មដូចខាងក្រោម៖

- គាំទ្រ និងលើកកម្ពស់ការជួយគ្នាទៅវិញទៅមករវាងអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- បង្កើនចំណេះដឹង បច្ចេកទេសស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ និង
- ជំរុញឲ្យមាននិរន្តរភាព និងការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។

### ប្រការ ៤._ អំពីសកម្មភាព

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានសកម្មភាពដូចតទៅ៖

- បង្កើតកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរ ចែករំលែកព័ត៌មាន បទពិសោធន៍ និងបច្ចេកទេសរវាងសមាជិកទាំងអស់
- ពង្រឹងសាមគ្គីភាព និងឯកភាពគ្នារវាងអ្នកផ្គត់ផ្គង់ទឹកស្អាត ដើម្បីជានាំឲ្យមានស្ថេរភាព និងភាពរីកចម្រើនដល់សង្គមជាតិ
- ពង្រឹងកិច្ចទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្គត់ផ្គង់ទឹកស្អាត និងស្ថាប័ននៃរាជរដ្ឋាភិបាល ស្ថាប័នជំនាញ និងភ្នាក់ងារអភិវឌ្ឍពាក់ព័ន្ធនានា

- លើកកម្ពស់ការផ្តល់សេវាទឹកស្អាតប្រកបដោយគុណភាព អនាម័យ និងនិរន្តរភាពជូនដល់អតិថិជន
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈឲ្យយល់ដឹងអំពីអត្ថប្រយោជន៍ នៃការប្រើប្រាស់ទឹកស្អាត
- ស្វែងរកទីផ្សារផ្គត់ផ្គង់សម្ភារ និងវត្ថុធាតុដើមសម្រាប់ការផលិត និងផ្គត់ផ្គង់ទឹកស្អាតដែលមានតម្លៃថោកសមរម្យប្រកបដោយគុណភាពសម្រាប់សមាជិកសមាគមទាំងអស់
- ស្វែងរកប្រភពធនធានផ្សេងៗសម្រាប់ជាប្រយោជន៍របស់សមាគមទាំងមូល
- បោះពុម្ពផ្សាយឯកសារ ព្រឹត្តិប័ត្រផ្សេងៗ និងវីដេអូ ដែលទាក់ទងដល់សកម្មភាពរបស់សមាគម និងវត្ថុបណ្តុះបណ្តាលនានា
- លើកទឹកចិត្តដល់សមាជិកទាំងអស់ក្នុងការបញ្ចេញមតិយោបល់ និងលើកយកបញ្ហាលំបាករបស់ខ្លួនមកពិភាក្សា ដើម្បីជាប្រយោជន៍ដល់សមាគមទាំងមូល
- តំណាងឲ្យសមាជិកគ្រប់រូបក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងកៀរគរជំនួយហិរញ្ញវត្ថុដើម្បីជួយដល់សមាជិកសមាគម ស្របតាមយុទ្ធសាស្ត្រ និងគោលនយោបាយរបស់សមាគម។

## <u>ជំពូកទី ២</u>

## ការកំណត់ឈ្មោះ ទីស្នាក់ការ អត្តសញ្ញាណ សញ្ញាសម្គាល់ និងត្រា

### ប្រការ ៥._ អំពីឈ្មោះ

សមាគមនេះ មានឈ្មោះថាជាភាសាខ្មែរថា "**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**" ដែលសរសេរជាអក្សរកាត់ "**ស.ទ.ក**" និងមានឈ្មោះជាភាសាអង់គ្លេសថា Cambodian Water Supply Association ដែលសរសេរជាអក្សរកាត់ "C.W.A" ។

### ប្រការ ៦._ អំពីទីស្នាក់ការ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ។

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា អាចមានទីស្នាក់ការសាខានៅតាមបណ្តាខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា តាមការចាំបាច់របស់ខ្លួន។

ការបើក ឬការបិទទីស្នាក់ការសាខា និងការផ្លាស់ប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាល ឬទីស្នាក់ការសាខារបស់សមាគមអាចធ្វើបានក្នុងករណីចាំបាច់ ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមរយៈសំឡេង ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣ (ពីរភាគបី) នៃក្រុមប្រឹក្សាភិបាល។

### ប្រការ ៧._ អំពីសញ្ញាសម្គាល់ និងត្រា

ក.អំពីសញ្ញាសម្គាល់៖

សញ្ញាសម្គាល់ជាផ្លូវការរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានរាងជារង្វង់មូលពណ៌ខៀវ ដោយមានខ្សែរង្វង់បីជាន់ ដោយពីរជាប់គ្នា និងមួយទៀតឃ្លាតឆ្ងាយទៅខាងក្នុង។ នៅក្នុងចន្លោះផ្ទៃខ្សែរង្វង់ទី២ និងខ្សែទី៣ មានរូបក្បាលនាគចំនួនពីរនៅសងខាង ដែលខណ្ឌចែករង្វង់ជាពីរផ្នែក។ ចំពោះផ្នែកខាងលើនៃរង្វង់មានចុះសរសេរឈ្មោះជាភាសាខ្មែររបស់សមាគម គឺ "**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**" និង

ផ្នែកខាងក្រោមនៃរង្វង់មានសរសេរឈ្មោះជាភាសាអង់គ្លេសរបស់សមាគមគឺ "**Cambodian Water Supply Association**"។ ចំណែកនៅចំកណ្តាលនៃរង្វង់ មានរូបអាងអាកាសស្តុកទឹកនៅពីមុខផែនទី នៃព្រះរាជាណាចក្រកម្ពុជា អមដោយដើមត្នោតបីដើមនៅផ្នែកខាងស្តាំ និងមានសរសេរអក្សរកាត់ នៃឈ្មោះជាភាសាខ្មែររបស់សមាគមគឺ "**ស.ទ.ក**" នៅផ្នែកខាងលើរូបអាងទឹក និងមានសរសេរអក្សរកាត់ នៃឈ្មោះជាភាសាអង់គ្លេសរបស់សមាគមគឺ "**C.W.A**" នៅផ្នែកខាងក្រោមរូបអាងទឹក។

អត្ថន័យ នៃសញ្ញាសម្គាល់របស់សមាគម មានដូចខាងក្រោម៖

<u>**អត្ថន័យដោយឡែក៖**</u>

- អក្សរ ស.ទ.ក និង C.W.A ៖ ជាអក្សរកាត់របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាភាសាខ្មែរ និងភាសាអង់គ្លេស
- ក្បាលនាគ ៖ តំណាងឲ្យប្រភពទឹក ភាពរុងរឿង ថ្កុំថ្កើង និងមានកេរ្តិ៍ឈ្មោះ
- រូបអាងអាកាស ៖ តំណាងឲ្យអ្នកផ្គត់ផ្គង់ទឹកស្អាត
- ដើមត្នោត និងផែនទីកម្ពុជា ៖ តំណាងទូទាំងប្រទេសកម្ពុជា។

<u>**អត្ថន័យជារួម**</u> គឺការរួបរួមគ្នារវាងអ្នកផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេសកម្ពុជា ដើម្បីធ្វើឲ្យការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតមានភាពរីកចម្រើន ថ្កុំថ្កើង រុងរឿងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ខ.អំពីត្រា៖**

ត្រារបស់សមាគម មានសណ្ឋានជារង្វង់មូលពីរជាន់ទំហំ ៣៤(សាមសិបបួន) មីល្លីម៉ែត្រ ដោយប្រើប្រាស់ដូចគ្នានឹងសញ្ញាសម្គាល់របស់សមាគម និងកំណត់ប្រើប្រាស់នូវទឹកល័ក្ខពណ៌ខៀវ។

### ប្រការ ៨._ អំពីអត្តសញ្ញាណ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឲ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

## <u>ជំពូកទី ៣</u>

## សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

### ប្រការ ៩._ អំពីសមាជិកភាព

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានសមាជិកបីប្រភេទ ដូចខាងក្រោម៖

**ក.សមាជិកស្ថាបនិក៖** គឺជាបុគ្គលដែលបានចូលរួមផ្តួចផ្តើមគំនិតបង្កើតសមាគមនេះឡើង ដោយបានចំណាយឧបត្ថម្ភសម្ភារ និងថវិកាដើម្បីឲ្យសមាគមបានដំណើរដោយការស្របច្បាប់។

**ខ.សមាជិកអាជីព ៖** គឺជានីតិបុគ្គល ឬរូបវន្តបុគ្គល ឬជាម្ចាស់សហគ្រាស ជាអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដែលបានទទួលប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម) ដែលបានដាក់ពាក្យស្នើសុំ

និងទទួលបានការអនុម័តឲ្យចូលជាសមាជិកអាជីពរបស់សមាគមដោយក្រុមប្រឹក្សាភិបាល។ សមាជិកអាជីពមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតជាសមាសភាពក្រុមប្រឹក្សាភិបាលរបស់សមាគម។

**គ.សមាជិកគាំទ្រ** ៖ គឺជាសមាជិកដែលបានចូលរួមផ្ដល់នូវមូលនិធិ សម្ភារ ថវិកា បទពិសោធន៍ ឬមានស្នាដៃល្អជួយសមាគមឲ្យមានការរីកចម្រើន ដែលអាចជានីតិបុគ្គល ឬរូបវន្តបុគ្គល ឬជាម្ចាស់សហគ្រាស ដែលពាក់ព័ន្ធការងារវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា អ្នកផ្គត់ផ្គង់សម្ភារ និងវត្ថុធាតុដើមគីមីសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ក្រុមហ៊ុនផ្តល់សេវាកម្ម ឬដៃគូអភិវឌ្ឍន៍ជាដើម។ ទន្ទឹមនេះ សមាគមបើកទូលាយចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានវិជ្ជាជីវៈផ្នែកទឹកស្អាត ក៏អាចចូលជាសមាជិកគាំទ្រផងដែរ។ សមាជិកគាំទ្រគ្មានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាភិបាលរបស់សមាគមឡើយ ប៉ុន្តែអាចចូលរួម និងបញ្ចេញមតិយោបល់នៅក្នុងកិច្ចប្រជុំ និងសន្និបាតរបស់សមាគម។

សមាជិកអាជីព និងសមាជិកគាំទ្រ អាចចាត់បញ្ជូនតំណាងម្នាក់ ឬច្រើននាក់ដើម្បីចូលរួមក្នុងកិច្ចប្រជុំ និងសន្និបាតរបស់សមាគម ប៉ុន្តែសមាជិកអាជីពមួយអាចមានសំឡេងបោះឆ្នោតបានតែមួយប៉ុណ្ណោះ។

## ប្រការ ១០._ អំពីការចូលជាសមាជិក

ការស្នើសុំចូលជាសមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត។

បុគ្គល ដែលមានបំណងសុំចូលជាសមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវដាក់ពាក្យសុំចូលជាសមាជិករបស់សមាគមទៅគណៈកម្មាធិការប្រតិបត្តិ និងត្រូវបំពេញនូវលក្ខខណ្ឌចាំបាច់មួយចំនួនខាងក្រោម៖

- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិក និងបំពេញកាតព្វកិច្ចសមាជិកភាព
- ជារូបវន្តបុគ្គលដែលមានអាយុចាប់ពី១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ ឬនីតិបុគ្គលដែលបានចុះបញ្ជីជាមួយស្ថាប័នមានសមត្ថកិច្ច ស្របតាមច្បាប់ពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា
- ទទួលបាននូវប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម) សម្រាប់ការសុំចូលជាសមាជិកអាជីព
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាប់ពិរុទ្ធពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

ការសម្រេចលើការស្នើសុំចូលជាសមាជិករបស់សមាគម ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដោយសេចក្តីសម្រេចតាមរយៈសំឡេង ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវរៀបចំបែបបទ នីតិវិធី លក្ខខណ្ឌលម្អិត និងគំរូពាក្យសុំចូលជាសមាជិករបស់សមាគម ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

## ប្រការ ១១._ អំពីវិភាគទានសមាជិកភាព

សមាជិកអាជីព និងសមាជិកគាំទ្រ មានកាតព្វកិច្ចបង់ប្រាក់វិភាគទានសមាជិកភាពប្រចាំឆ្នាំតាមការកំណត់។ ការបង់វិភាគទាននេះ អាចបង់ប្រាំមួយខែម្តង។

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ថ្លៃវិភាគទានសមាជិកភាព និងអាចការកែប្រែថ្លៃវិភាគទាននេះបាន តាមការចាំបាច់ ដោយសេចក្តីសម្រេចតាមរយៈសំឡេង ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុម ចូលរួម ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

## ប្រការ ១២._ អំពីការបាត់បង់សមាជិកភាព

សមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា អាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយករណីណាមួយដូចខាងក្រោម៖

- ការដាក់លិខិតលាឈប់ជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាភិបាល
- ខកខានក្នុងការបង់វិភាគទានដល់សមាគមក្នុងរយៈពេល៦(ប្រាំមួយ)ខែ
- ទទួលមរណភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈការងារ ឬការប្រកាសក្ស័យធន ឬការរំលាយនីតិបុគ្គល
- បាត់បង់ប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលផ្តល់ឲ្យដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម)
- មានជាប់ពិរុទ្ធដាក់ពន្ធនាគារពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយ
- មានជំងឺវិបល្លាសស្មារតី ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមការសម្រេចដកសមាជិកភាពដោយកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល តាមរយៈសំឡេងអនុម័ត ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកូរ៉ុមចូលរួម ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល ក្នុងករណីដែលសមាជិកណាមិនគោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់សមាគម ដែលបង្កឲ្យមានការខូចខាតដល់ផលប្រយោជន៍របស់សមាគមទាំងមូល
- សមាគមត្រូវបានប្រកាសរំលាយ។

## ប្រការ ១៣._ អំពីការជ្រើសរើសបុគ្គលិក

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិក តាមសេចក្តីត្រូវការចាំបាច់របស់ខ្លួន ដើម្បីតម្រូវការកម្មវិធីនានា ដោយប្រកាសជ្រើសរើស និងធ្វើឡើងដោយមានកិច្ចសន្យាការងារជាក់លាក់ជាមួយសមាគម។ ការជ្រើសរើសបុគ្គលិកត្រូវអនុលោមតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអន្តោប្រវេសន៍ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម។

## ប្រការ ១៤._ អំពីតួនាទី ភារកិច្ចរបស់សមាជិក និងបុគ្គលិក

គ្រប់សមាជិក និងបុគ្គលិកទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។

គ្រប់សមាជិក និងបុគ្គលិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវបំពេញការងារតាម តួនាទីភារកិច្ចរបស់ខ្លួនទៅតាមការកំណត់ ដូចមានចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគម។

# ជំពូកទី ៤
# អំពីរចនាសម្ព័ន្ធដឹកនាំ

## ប្រការ ១៥._ អំពីរចនាសម្ព័ន្ធដឹកនាំ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានរចនាសម្ព័ន្ធដឹកនាំ ដូចខាងក្រោម៖

- សន្និបាត
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការប្រតិបត្តិ។

## ប្រការ ១៦._ អំពីសន្និបាត

សន្និបាត គឺជាស្ថាប័នដឹកនាំកំពូលរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ សន្និបាតរបស់សមាគមនេះមាន២ប្រភេទ គឺសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ។

សន្និបាតសាមញ្ញ ប្រារព្ធឡើងរៀងរាល់មួយឆ្នាំម្តង។ ក្នុងករណីចាំបាច់ សមាគមអាចរៀបចំសន្និបាតវិសាមញ្ញរបស់ខ្លួនបានដោយមិនកំណត់រយៈពេល តាមការកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាភិបាល ឬតាមរយៈប្រធានក្រុមប្រឹក្សាភិបាល នៅពេលមានសំណើ ១/៣(មួយភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវជូនដំណឹងទៅសមាជិកអាជីព សមាជិកគាំទ្រ និង/ឬគ្រប់អ្នកពាក់ព័ន្ធទាំងអស់ អំពីទីកន្លែង ពេលវេលា និងរបៀបវារៈ នៃអង្គសន្និបាតយ៉ាងតិច១០(ដប់)ថ្ងៃ មុនថ្ងៃប្រារព្ធសន្និបាត។

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសន្និបាត។ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន អនុប្រធានក្រុមប្រឹក្សាភិបាលត្រូវដឹកនាំអង្គប្រជុំសន្និបាតជំនួស តាមរយៈលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ។ ករណីដែលប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន ការជ្រើសរើសប្រធានសន្និបាត ជាភារកិច្ចរបស់អង្គសន្និបាត។

## ប្រការ ១៧._ អំពីតួនាទី និងភារកិច្ចរបស់សន្និបាត

សន្និបាត មានភារកិច្ចសម្រេចកិច្ចការដូចខាងក្រោម៖

- បោះឆ្នោតកំណត់ចំនួនសមាជិកក្រុមប្រឹក្សាភិបាល និងបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល នៅពេលចប់អាណត្តិ
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈសមាគម
- ពិនិត្យ និងអនុម័តលើផែនការយុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗ
- ពិនិត្យ និងអនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានអនុវត្តកន្លងមក
- ពិនិត្យ និងអនុម័តផែនការសកម្មភាពការងារ និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តឆ្នាំបន្ទាប់របស់សមាគម
- ពិនិត្យ និងអនុម័តលើសំណើនានា ដែលក្រុមប្រឹក្សាភិបាលមិនអាចសម្រេចបាន
- ពិនិត្យ និងអនុម័តលើការរំលាយសមាគម និងការចាត់ចែងទ្រព្យសម្បត្តិរបស់សមាគមនៅពេលរំលាយ
- ពិនិត្យ និងដោះស្រាយបញ្ហាចាំបាច់ និងបន្ទាន់ផ្សេងៗទៀត។

## ប្រការ ១៨._ អំពីលក្ខណៈគតិយុត្ត

សន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ មានតម្លៃស្មើគ្នា។ រាល់សេចក្តីសម្រេចនានារបស់សន្និបាតទាំងពីរប្រភេទនេះ មានតម្លៃគតិយុត្តទៅបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រ ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកអាជីពទាំងអស់ក្នុងសមាគម។ ក្នុងករណីការអនុម័តមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានសន្និបាតមានឧត្តមានុភាព។

កូរ៉ុមរបស់សន្និបាតតម្រូវឲ្យមានវត្តមានសមាជិកលើសពី២/៣ (ពីរភាគបី) នៃចំនួនសមាជិកអាជីព។

ប្រសិនបើកូរ៉ុមមិនគ្រប់តាមការកំណត់ខាងលើទេ ប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញជាលើកទីពីរនៅក្នុងរយៈពេល ១៤(ដប់បួន)ថ្ងៃក្រោយ។ សម្រាប់ការកោះអញ្ជើញជាលើកទីពីរនេះ កូរ៉ុមរបស់សន្និបាតតម្រូវឲ្យមានវត្តមានសមាជិកលើសពី ៥០%+១(ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកអាជីព។

## ប្រការ ១៩._ អំពីក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ដឹកនាំ គ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវលើសកម្មភាពការងារនានារបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដើម្បីសម្រេចឲ្យបានតាមទស្សនៈវិស័យ និងគោលបំណងរបស់សមាគម។

ក្រុមប្រឹក្សាភិបាលត្រូវមានសមាសភាពចាប់ពី៥រូបឡើងទៅ ដោយត្រូវកំណត់ជាចំនួនសេសអាស្រ័យទៅតាមចំនួនសមាជិក និងការសម្រេចរបស់សន្និបាត។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែមានសមាសភាពតំណាងមកពីនីតិបុគ្គលយ៉ាងតិចចំនួន ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាលក្នុងអាណត្តិ។ រាល់សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែជាបុគ្គលសញ្ជាតិខ្មែរ។

សមាសភាពក្រុមប្រឹក្សាភិបាល រួមមាន៖ ប្រធាន១(មួយ)រូប អនុប្រធាន១(មួយ)រូប ហេរញ្ញិក១(មួយ)រូប និងសមាជិកយ៉ាងតិចចាប់ពី២(ពីរ)រូបឡើងទៅ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ ប្រការ១៩ នៃលក្ខន្តិកៈនេះ។ សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ដោយសន្និបាតសមាគម។ បេក្ខជនដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេនឹងត្រូវជាប់ជាប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានសមាគម ចំណែកបេក្ខជនដែលបានទទួលសំឡេងឆ្នោតច្រើនបន្ទាប់នឹងត្រូវជាប់ជាអនុប្រធានក្រុមប្រឹក្សាភិបាល។ ចំណែកឯហេរញ្ញិកត្រូវជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាភិបាល។

ប្រសិនបើមានបេក្ខភាព នៃតំណែងណាមួយ ទទួលបានសំឡេងឆ្នោតគាំទ្រស្មើគ្នា នោះបេក្ខជនដែលមានអាយុច្រើនជាងគេត្រូវទទួលបានតំណែងនោះ។

## ប្រការ ២០._ អំពីប្រធានក្រុមប្រឹក្សាភិបាល

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងជាតំណាងស្របច្បាប់របស់សមាគមដែលមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវរាល់សកម្មភាពរបស់សមាគម។

## ប្រការ ២១._ អំពីអនុប្រធានក្រុមប្រឹក្សាភិបាល

អនុប្រធានក្រុមប្រឹក្សាភិបាល គឺជាអនុប្រធានសមាគម។ អនុប្រធានសមាគម ជាសេនាធិការឲ្យប្រធានសមាគម និងមានតួនាទីជំនួសប្រធាននៅពេលប្រធានអវត្តមានក្នុងឋានៈជាប្រធានស្តីទី ដោយមាន

លិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានសមាគម និងបំពេញការងារមួយចំនួនទៀតតាមការចាត់ចែងរបស់ប្រធាន។

## ប្រការ ២២._ អំពីហេរញ្ញិក

ហេរញ្ញិក ត្រូវបំពេញតួនាទីជាអ្នកជានាឲ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់សមាគមមានភាពត្រឹមត្រូវ។ ហេរញ្ញិកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូលចំណាយរបស់សមាគម ព្រមទាំងផ្តល់កិច្ចសហការក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម និងបំពេញការងារមួយចំនួនទៀតតាមការចាត់ចែងរបស់ប្រធាន។

## ប្រការ ២៣._ អំពីសមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល មានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំក្រុមប្រឹក្សាភិបាល និងចូលរួមធ្វើសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាភិបាល។ សមាជិកក្រុមប្រឹក្សាភិបាលអាចទទួលបន្ទុកការងារផ្សេងៗទៀត តាមការបែងចែកដោយប្រធានក្រុមប្រឹក្សាភិបាល។

## ប្រការ ២៤._ អំពីអាណត្តិរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានអាណត្តិការងាររយៈពេល៤(បួន)ឆ្នាំ។

ប្រធាន និងអនុប្រធានអាចបម្រើការពីរអាណត្តិជាប់គ្នា ស្មើនឹង៨(ប្រាំបី)ឆ្នាំ ប្រសិនបើបេក្ខភាពរបស់ខ្លួនត្រូវបានបោះឆ្នោតជ្រើសរើសសារជាថ្មីដោយសន្និបាត។

សមាជិកក្រុមប្រឹក្សាភិបាលផ្សេងទៀត អាចបន្តអាណត្តិរបស់ខ្លួនដោយគ្មានកាលកំណត់ ប្រសិនបើបេក្ខភាពរបស់ខ្លួនត្រូវបានបោះឆ្នោតជ្រើសរើសសារជាថ្មីដោយសន្និបាត។

ចំពោះបេក្ខជនដែលជាអតីតប្រធាន ឬអតីតអនុប្រធាន អាចឈរឈ្មោះឲ្យគេបោះឆ្នោតត្រឹមជាសមាជិកក្រុមប្រឹក្សាភិបាលបាននៅអាណត្តិថ្មី បន្ទាប់ពីកាន់មុខតំណែងរយៈពេលពីរអាណត្តិជាប់គ្នាស្មើនឹង៨ (ប្រាំបី)ឆ្នាំ។

## ប្រការ ២៥._ អំពីគុណវុឌ្ឍិសម្រាប់ឈរឈ្មោះជាក្រុមប្រឹក្សាភិបាល

បេក្ខភាពដែលអាចឈរឈ្មោះ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានលុះត្រាតែជា អាជីវករ ឬពាណិជ្ជករនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត មានគុណវុឌ្ឍិដូចខាងក្រោម៖

- មានអាយុចាប់ពី២៥(ម្ភៃប្រាំ)ឆ្នាំឡើងទៅ និងសញ្ជាតិខ្មែរ
- ជាសមាជិកស្ថាបនិក ឬសមាជិកអាជីព
- ទទួលបាននូវប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម)
- មានបទពិសោធន៍ក្នុងសកម្មភាពវិស័យផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនយ៉ាងតិច២(ពីរ)ឆ្នាំឡើងទៅ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាប់ពិរុទ្ធពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

**ប្រការ ២៦._ អំពីការបាត់បង់សមាជិកភាពរបស់ក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ អាចបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព
- បានដាក់លិខិតលាលែងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងតិច១(មួយ)ខែ មុនថ្ងៃឈប់ជូនប្រធានក្រុមប្រឹក្សាភិបាល ឬជូនអនុប្រធាន ក្នុងករណីប្រធានលាលែង
- បាត់បង់សមាជិកភាពពីសមាគម
- បាត់បង់ប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណដែលផ្តល់ឲ្យដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ពីមុនក្រសួងឧស្សាហកម្ម និងសិប្បកម្ម)
- មានជាប់ពិរុទ្ធដាក់ពន្ធនាគារពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ
- មានជំងឺវិបល្លាសស្មារតី ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា
- សមាជិកដែលមិនបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ៣(បី)ដងជាប់ៗគ្នាជាបន្តបន្ទាប់ ដោយគ្មានមូលហេតុច្បាស់លាស់ ឬពុំបានជូនដំណឹងដល់ប្រធានក្រុមប្រឹក្សាភិបាល។

**ប្រការ ២៧._ អំពីតួនាទី និងមុខងាររបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលមានតួនាទី និងមុខងារ ដូចតទៅ៖

- ពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ
- ពិនិត្យ និងអនុម័តលើបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌របស់សមាគម
- ធានានូវការអនុវត្តឲ្យបានត្រឹមត្រូវតាមគោលនយោបាយ យុទ្ធសាស្ត្រ និងលក្ខន្តិកៈរបស់សមាគម
- តាក់តែង និងស្នើផែនការយុទ្ធសាស្ត្រ និងផែនការថវិកាប្រចាំឆ្នាំសម្រាប់សមាគមដាក់ជូនសន្និបាតធ្វើការអនុម័ត
- ធានាលើការគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានភាពត្រឹមត្រូវ ប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកា
- អនុម័តកម្មវិធីកសាងសមត្ថភាពរបស់សមាគម
- អនុម័តគោលនយោបាយរដ្ឋបាល និងបុគ្គលិក
- អនុម័ត និងកែប្រែវិភាគទានសមាជិកភាពប្រចាំឆ្នាំ
- ជួយកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីធានានិរន្តរភាពរបស់សមាគម
- តាក់តែងសេចក្តីពិពណ៌នាអំពីការងារ និងការទទួលខុសត្រូវរបស់នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងទៀតរបស់សមាគម
- ជ្រើសរើស តែងតាំង ព្យួរការងារ ឬបញ្ឈប់ការងាររបស់នាយកប្រតិបត្តិ។ ក្រុមប្រឹក្សាភិបាលអាចផ្ទេរអំណាចក្នុងការជ្រើសរើសតែងតាំង ព្យួរការងារ ឬបញ្ឈប់ការងាររបស់បុគ្គលិកផ្សេងទៀតជូននាយកប្រតិបត្តិ
- គ្រប់គ្រងការបើកដំណើរការ និងការបិទគណនីធនាគាររបស់សមាគម និងអាចផ្តល់សិទ្ធិក្នុងការប្រើប្រាស់គណនីសមាគមឲ្យទៅសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈគ្រប់គ្រង នៃគណៈកម្មាធិការប្រតិបត្តិរបស់សមាគម

- ចុះកិច្ចព្រមព្រៀងធ្វើជាដៃគូជាមួយអង្គការផ្សេងៗ តាមការចាំបាច់ និងធានាការអនុវត្តកិច្ចព្រមព្រៀងមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព
- ជួលទីប្រឹក្សា ឬអ្នកជំនាញផ្សេងៗ ក្នុងការរៀបចំផែនការ ឬវិធានការផ្សេងៗ សម្រាប់ដាក់ជូនសន្និបាតធ្វើការអនុម័ត។

## ប្រការ ២៨._ អំពីកិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិច៣(បី)ខែម្តង ឬអាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាភិបាល ឬតាមរយៈប្រធានក្រុមប្រឹក្សាភិបាល នៅពេលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាភិបាល ៣(បី)រូប និង/នាយកប្រតិបត្តិ។

ការជូនដំណឹង និងរបៀបវារៈកិច្ចប្រជុំ ត្រូវផ្ញើទៅសមាជិកគ្រប់រូបឲ្យបាន ១០(ដប់)ថ្ងៃមុនកិច្ចប្រជុំ។ ការជូនដំណឹងពីកិច្ចប្រជុំត្រូវមានព័ត៌មានអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលា។ ចំពោះប្រធាន ឬអនុប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាលណាដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវជូនដំណឹងទៅប្រធាន ឬអនុប្រធាន ក្រុមប្រឹក្សាភិបាលឲ្យបានយ៉ាងតិច២(ពីរ)ថ្ងៃមុនកិច្ចប្រជុំ។ ករណីប្រធានអវត្តមាន ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ។

កូរ៉ុម តម្រូវឲ្យមានសមាជិកក្រុមប្រឹក្សាភិបាល ២/៣ (ពីរភាគបី) មានវត្តមានក្នុងអង្គប្រជុំ។

លើកលែងតែក្នុងករណីចែងផ្សេងពីនេះ សេចក្តីសម្រេចរបស់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាចមានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រ ៥០%+១ (ហាសិបភាគរយបូកមួយ) និងត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ របាយការណ៍ នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ នៅក្នុងករណីមានសំឡេងស្មើគ្នានៅពេលធ្វើសេចក្តីសម្រេចផ្សេងៗ សំឡេងរបស់ប្រធានត្រូវមានឧត្តមានុភាព។

នៅក្នុងករណីដែលកូរ៉ុមមានមិនគ្រប់ សមាជិកដែលមានវត្តមាននៅពេលប្រជុំអាចធ្វើការប្រជុំបាន ប៉ុន្តែមិនអាចធ្វើសេចក្តីសម្រេចអ្វីបានទេ គឺអាចត្រឹមតែធ្វើសំណើសម្រាប់កិច្ចប្រជុំលើកក្រោយប៉ុណ្ណោះ។

ត្រូវរក្សាទុកទាំងស្រុងនូវកំណត់ត្រាកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាភិបាល។ កំណត់ហេតុរបាយការណ៍កិច្ចប្រជុំនីមួយៗនឹងត្រូវអនុម័ត នៅក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាភិបាល។ សមាជិកត្រូវបញ្ជាក់ការយល់ព្រមរបស់ខ្លួន ដោយចុះហត្ថលេខានៅលើទំព័រមុខ នៃកំណត់ហេតុកិច្ចប្រជុំកន្លងទៅ។

## ប្រការ ២៩._ អំពីអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល អាចអញ្ជើញអ្នកតំណាងមកពីស្ថាប័ននៃរាជរដ្ឋាភិបាល ឬអង្គការផ្សេងៗ ធ្វើជាអ្នកអង្កេតការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ នាយកប្រតិបត្តិ ជាអ្នកសង្កេតការណ៍អង្គប្រជុំដោយស្វ័យប្រវត្តិ។ អ្នកសង្កេតការណ៍គ្មានសិទ្ធិបោះឆ្នោតទេ។ ក្រុមប្រឹក្សាភិបាលអាចស្នើសុំឲ្យអ្នកសង្កេតការណ៍ចេញពីបន្ទប់ប្រជុំ ប្រសិនបើមានការពិភាក្សាលើការសម្ងាត់។

## ប្រការ ៣០._ អំពីគណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិ ត្រូវដឹកនាំដោយនាយកប្រតិបត្តិ១(មួយ)រូប និងបុគ្គលិកផ្សេងៗទៀត ដោយគោរពតាមគោលការណ៍វិជ្ជាជីវៈ តម្លាភាព និងការប្រកួតប្រជែង។ នាយកប្រតិបត្តិ ត្រូវតែងតាំងដោយ

សេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានការបោះឆ្នោតអនុម័តសម្រេចដោយកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

ការតែងតាំងបុគ្គលិកដទៃទៀត ត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយមានការចូលរួមជ្រើសរើសពីនាយកប្រតិបត្តិ។ ក្រុមប្រឹក្សាភិបាលអាចផ្ទេរអំណាចក្នុងការជ្រើសរើស និងតែងតាំងបុគ្គលិកផ្សេងៗឲ្យទៅនាយកប្រតិបត្តិបាន។

**ប្រការ ៣១._ អំពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ**

ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការប្រតិបត្តិ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ សេចក្ដីសម្រេចនេះ ត្រូវមានខ្លឹមសារសំខាន់ជាអាទិ៍ ដោយមានសេចក្ដីពិពណ៌នាអំពីការជ្រើសរើស ការបញ្ឈប់ និងការទទួលខុសត្រូវរបស់នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងៗទៀត តួនាទីនិងភារកិច្ច នៃចនាសម្ព័ន្ធរបស់គណៈកម្មាធិការប្រតិបត្តិជាដើម។ សេចក្ដីសម្រេចនេះ អាចកែប្រែក្នុងករណីចាំបាច់។

គណៈកម្មាធិការប្រតិបត្តិ ត្រូវគោរពរដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្ដីសម្រេចផ្សេងៗរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។

**ប្រការ ៣២._ អំពីប្រាក់បំណាច់មុខងារ**

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ប្រាក់បំណាច់មុខងារ និងផលប្រយោជន៍ផ្សេងៗរបស់នាយកប្រតិបត្តិ និងបុគ្គលិកដទៃទៀត។

## ជំពូកទី ៥

## ប្រភព និងវិធានការនៃគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ ៣៣._ អំពីប្រភពធនធាន និងទ្រព្យសម្បត្តិ**

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាមានប្រភពធនធានមកពី៖

- ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៣៤._ អំពីការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ**

រាល់ចំណូលទាំងអស់របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវបានគ្រប់គ្រងដោយហេរញ្ញិក និងត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល។

រាល់ការចំណាយដែលជាផលប្រយោជន៍របស់សមាគមត្រូវមានការអនុញ្ញាតពីប្រធានសមាគម។ ប្រធានសមាគមអាចផ្ទេរអំណាចសម្រេចលើការចំណាយណាមួយឲ្យទៅនាយកប្រតិបត្តិ តាមរយៈលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។

ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រទាំងអស់ត្រូវបញ្ចូលទៅក្នុងធនាគារស្របច្បាប់ណាមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាម **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** តាមការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។

សមាជិកក្រុមប្រឹក្សាភិបាល មិនអាចទទួលប្រាក់ឧបត្ថម្ភផ្សេងៗពីមូលនិធិ ឬទ្រព្យសម្បត្តិរបស់សមាគម ក្នុងឋានៈខ្លួនជាសមាជិកក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែប្រាក់ទូទាត់សងចំពោះថ្លៃចំណាយ លើការមកចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ការទូទាត់សងនេះត្រូវកំណត់ និងអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ប្រការ ៣៥._ អំពីឆ្នាំហិរញ្ញវត្ថុ និងផែនការថវិកា**

ឆ្នាំហិរញ្ញវត្ថុរបស់សមាគមត្រូវបានកំណត់ចាប់ផ្តើមនៅថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ។

ផែនការថវិកាត្រូវរៀបចំដោយក្រុមប្រឹក្សាភិបាល ដោយធ្វើការពិគ្រោះយោបល់ជាមួយនាយកប្រតិបត្តិ។ ផែនការថវិកានេះត្រូវពិនិត្យ និងអនុម័តយល់ព្រមដោយសន្និបាតសមាគម។

**ប្រការ ៣៦._ អំពីការធ្វើសវនកម្ម**

របាយការណ៍ហិរញ្ញវត្ថុរបស់សមាគម ត្រូវធ្វើសវនកម្មជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីហេរញ្ញិក។

ក្រុមប្រឹក្សាភិបាលអាចតែងតាំងហេរញ្ញិក ឬសមាជិកម្នាក់ទៀតឲ្យចូលរួមជាមួយសវនករខាងក្រៅម្នាក់ ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីធ្វើសវនកម្មយ៉ាងហោចណាស់ ៣(បី)ឆ្នាំម្តង។

ទាំងសវនករខាងក្នុង និងខាងក្រៅត្រូវដាក់របាយការណ៍សវនកម្មជូនក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ។ របាយការណ៍សវនកម្មនានាចាំបាច់ត្រូវពិនិត្យឡើងវិញដោយហេរញ្ញិក និងត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាល។

## ជំពូកទី ៦

## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

**ប្រការ ៣៧._ អំពីវិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ**

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា អាចប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់ ឬធ្វើវិសោធនកម្មលក្ខន្តិកៈ បានតាមសំណើសុំរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកក្រុមប្រឹក្សាភិបាលចំនួន១/៣(១ភាគ៣) ឬសមាជិកអាជីពរបស់សមាគមចំនួន ២០%(ម្ភៃភាគរយ) ។ ការអនុម័តសម្រេចលើការប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សមាគមនេះ ជាសមត្ថកិច្ចរបស់សន្និបាតដោយមានសំឡេងគាំទ្រ៥០%+១ (ហាសិបភាគរយបូកមួយ) នៃសមាជិកអាជីពទាំងអស់របស់សមាគម។

## ជំពូកទី ៧

## ការផ្អាកសកម្មភាព ការរំលាយ និងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ ៣៨._ អំពីការផ្អាកសកម្មភាពសមាគម**

មានតែសន្និបាតតែមួយគត់ ដែលមានសិទ្ធិសម្រេចផ្អាកសកម្មភាពរបស់ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** នេះបាន។ នៅពេលសមាគមត្រូវបានផ្អាកសកម្មភាព សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់សមាគម។

**ប្រការ ៣៩._ អំពីការរំលាយសមាគម**

មានតែសន្និបាតតែមួយគត់ ដែលមានសិទ្ធិសម្រេចរំលាយ**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**ដោយមានសំឡេងគាំទ្រ២/៣ (ពីរភាគបី) របស់សមាជិកអាជីពទាំងអស់របស់សមាគម។

ចំពោះការរំលាយ សមាគមត្រូវធ្វើការជូនដំណឹងឲ្យដល់គ្រប់សមាជិកស្ថាបនិក សមាជិកអាជីព សមាជិកគាំទ្រ បុគ្គលិក និងដៃគូពាក់ព័ន្ធផ្សេងៗ រួមទាំងម្ចាស់ជំនួយ និងស្ថាប័ននៃរាជរដ្ឋាភិបាលដែលពាក់ព័ន្ធឲ្យបានយ៉ាងតិចចំនួន ៣(បី)ខែ មុនថ្ងៃរំលាយសមាគម។

**ប្រការ ៤០._ អំពីការចាត់ចែងធនធាន និងទ្រព្យសម្បត្តិពេលរំលាយសមាគម**

នៅក្នុងករណីដែលមានមូលនិធិ ឬទ្រព្យសម្បត្តិនៅសេសសល់បន្ទាប់ពីការសងបំណុលផ្សេងៗរួចហើយក្រុមប្រឹក្សាភិបាលត្រូវត្រួតពិនិត្យ និងអនុម័តយល់ព្រមលើការចាត់ចែងទ្រព្យសម្បត្តិទាំងអស់នោះទៅឲ្យអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមមិនស្វែងរកប្រាក់ចំណេញដទៃទៀត ដែលមានបេសកកម្មប្រហាក់-ប្រហែលគ្នា។ ក្នុងករណីសមាគមនៅមានជាប់បំណុល សមាជិកម្នាក់ៗ ទទួលខុសត្រូវ ត្រឹមតែចំនួនប្រាក់វិភាគទានសមាជិកភាពដែលបានបង់ប្រចាំឆ្នាំតែប៉ុណ្ណោះ។

សមាជិក និងបុគ្គលិកសមាគមទាំងអស់ក៏ត្រូវរំលាយផងដែរ នៅពេលសមាគមត្រូវបានរំលាយ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**ប្រការ ៤១._**

ចំពោះសមាសភាពក្រុមប្រឹក្សាភិបាលរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមសម្រាប់នីតិបុគ្គលក្នុងអាណត្តិដំបូងនេះ ត្រូវអនុវត្តតាមស្មារតី នៃលិខិតលេខ ៨៤៦សជណ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ រហូតដល់ចប់អាណត្តិការងាររបស់ខ្លួន។

សម្រាប់អាណត្តិបន្តបន្ទាប់ ការជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាលរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវអនុវត្តតាមការកំណត់ក្នុងប្រការ១៩ ប្រការ២៤ និងប្រការ២៥ នៃលក្ខន្តិកៈនេះ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**ប្រការ ៤២._**

**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ត្រូវធ្វើសកម្មភាពរបស់ខ្លួនស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

**ប្រការ ៤៣._**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

ស.អ

**ប្រការ ៤៤._**

លក្ខន្តិកៈរបស់ **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាលនេះតទៅ។

ថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ឡេង ឡៀង**

**បានតម្កល់ទុកលក្ខន្តិកៈ**

របស់

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស

លេខៈ២៩០១ ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០២១។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០២១

**នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ**

**ប្រធាន**

ឈឹម គាន

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី១

# សញ្ញាសម្គាល់ និងត្រា

# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)

Cambodian Water Supply Association (C.W.A)

(**នីតិបុគ្គល**)

**ក. អំពីសញ្ញាសម្គាល់**

**ខ. អំពីត្រា**

ថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ឡេង ឡៀង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី ២

# រចនាសម្ព័ន្ធ

# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)

Cambodian Water Supply Association (C.W.A)

(នីតិបុគ្គល)




ថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ឡេង ខៀង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឧបសម្ព័ន្ធទី ៣

## សមាសភាពអ្នកដឹកនាំ (អាណត្តិដំបូង)

## សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)

Cambodian Water Supply Association (C.W.A)

(នីតិបុគ្គល)

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | រចនាសម្ព័ន្ធ | តួនាទី | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ឡេង ខៀវ | ប្រុស | ក្រុមប្រឹក្សាភិបាល | ប្រធាន | |
| ២ | ហម ងួន | ប្រុស | ក្រុមប្រឹក្សាភិបាល | អនុប្រធាន | |
| ៣ | សៀ សេងហ៊ាប | ប្រុស | ក្រុមប្រឹក្សាភិបាល | ហេរញ្ញិក | |
| ៤ | ជា សំបូរ | ប្រុស | ក្រុមប្រឹក្សាភិបាល | សមាជិក | |
| ៥ | ចាន់ ថានី | ប្រុស | ក្រុមប្រឹក្សាភិបាល | សមាជិក | |
| ៦ | សៀវ ហួត | ប្រុស | ក្រុមប្រឹក្សាភិបាល | សមាជិក | |
| ៧ | ហៀក អេងឡាយ | ប្រុស | ក្រុមប្រឹក្សាភិបាល | សមាជិក | |
| ៨ | យ៉ាន ជីតា | ស្រី | ក្រុមប្រឹក្សាភិបាល | សមាជិក | |
| ៩ | លាង បញ្ញា | ប្រុស | ក្រុមប្រឹក្សាភិបាល | សមាជិក | |

**សម្គាល់៖** សមាសភាពក្រុមប្រឹក្សាភិបាលខាងលើនេះ ត្រូវបានក្រសួងមហាផ្ទៃសម្រេចទទួលស្គាល់តាមរយៈលិខិតលេខ ៨៤៦សជណ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។

លក្ខន្តិកៈ ស.អ

ថ្ងៃចន្ទ ១៣រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

ស.ទ.ក C.W.A CAMBODIAN WATER SUPPLY ASSOCIATION

**ឡេង ខៀវ**